យើងធ្វើរួចហើយ ។ ទេអ្នកត្រូវតែប្រតិបត្តិស្វ៍ឡាត់ ព្រោះស្វ៍ឡាត់ខ្ពស់ជាងសម្លេងស្រែកទាំងឡាយ ។ បណ្ដាស្នៃត្បូនខ្លាចស្វ៍ឡាត់និងម៉ាស់ឃ្មិដ្ធ ។»

ពោលខាងលើនេះគឺផលប្រយោជន៍ និងផលបុណ្យរបស់ស្វ៍ឡាត់ ។ ដូច្នេះ ស្វ៍ឡាត់ជាការបណ្ដុះបណ្ដាលចិត្តឲ្យកើតមានសទ្ធាដ៏ខ្លាំងក្លា ព្រោះស្វ៍ឡាត់ជាអ៊ីបាដាស់ដ៏ធំធេងមហិមា ។



# الصلاة

# អាស្វ់ស្វ៍ឡាត់



អាស្វ់លុល-បៃត៍ عليهم السلام
បោះពុម្ពលើកទី ១
មិថុនា គ. ស. ២០១០

ឧបសគ្គទាំងឡាយឲ្យខ្ទេចខ្ទីអស់ ។"

ពេលស្ម៏ឡាត្ម៏ចប់ស្រេចហើយ ជាការល្អប្រសើរឲ្យឌូអាអ៏ និងអង្វរសូមអ្វីដែលយើងប្រាថ្នា ដើម្បីនឹងឲ្យស្ម៏ឡាត្ម៏គ្រាប់គ្រាន់បរិបូរ ។ កុំអាលក្រោកចេញពីស្ម៏ឡាត្ម៏ ការសូមឌូអាអ៏ជាការល្អប្រពៃ ចូរធ្វើក្រោយពីស្ម៏ឡាត្ម៏រួច ។

ការសូត្រគួរអានក្រោយស្ម៏ឡាត្ម៏ ការធ្វើអ៊ីសទីក្ហ្វារ (استغفار, ការសូមខមាទោស), ការសូត្រស្ម៏ឡាវ៉ាត, ការសូត្រឌូអាអ៏ផ្សេងៗ, ការបួងសួងសូមអ្វីមួយដែលខ្លួនប្រាថ្នា, ការសូត្រតាស់ប៊ីះហ្ វ៍ (تسبيح) ព្រះនាងហ្វាទីម៉ាស់ﷺ, ការស៊ូឃ្ជូដ អាស្ស៊ុក្រ (ក្រាបអរព្រះគុណអល់ឡោះហ្វ៍ عز وجل), និងធ្វើល្អផ្សេងៗ ទុកជាការធ្វើអ៊ីបាដ្ហាស់មួយ ។

ការសូត្រតាស់ប៊ីះហ្ វ៍ ព្រះនាងហ្វាទីម៉ាស់ سلام الله عليها, ឲ្យធ្វើក្រោយស្ម៏ឡាត្ម៏រួច, គឺសូត្រ អល់ឡ៊ហ្វ៍ អាក់បារ (أكبر الله ) ៣៤ ដង, សូត្រ អាល់ហ្វាំឌូលិលឡាហ្វ៍ ៣៣ ដង (الحمد لله), និងសូត្រ ស៊ុបហាណាល់ឡោះហ្វ៍ (سبحان الله) ៣៣ ដង ។ ឌូអាអ៏នេះមានផលបុណ្យច្រើនណាស់ ជាឌូអាអ៏ដែលណាប៊ីមូហ្វាំម៉ាដ្ឋ صلى الله عليه وآله وسلم បានបង្រៀន ឲ្យចំពោះតែបុត្រីសម្លាញ់របស់ព្រះអង្គ صلى الله عليه وآله وسلم ម្នាក់ប៉ុណ្ណោះ គឺម្ចាស់ស្ត្រីហ្វាទីម៉ាស់ سلام الله عليها ដូច្នេះហើយបានជាហៅថា "តាស់ប៊ីះហ្ វ៍ ព្រះនាងហ្វាទីម៉ាស់ سلام الله عليها" ។

ការធ្វើ ស៊ូឃ្ជូដ អាស្ស៊ុក្រ (ក្រាបអរព្រះគុណអល់ឡោះហ្វ៍ عز وجل) ជាអ៊ីបាដ្ហាស់មួយទៀត ដោយក្រាបព្រមទាំងសូត្រថា៖ "អាល់ហាំឌូលិលឡាស់ ស្ស៊ុករ៉ន់លិលឡាស់ អាល់-អាហ្វ៊ូរ យ៉ារ៉ប់ យ៉ារ៉ប់"។ អ៊ីម៉ាំយូម៉ែនី رضي الله عنه មានប្រសាសន៍ថា៖ «ក្នុងសាសនាអ៊ីស្លាមពុំមានអ្វីមួយដែលមានបទបញ្ញត្តិលើសស្ម៏ឡាត្ម៏ឡើយ ។ ស្ម៏ឡាត្ម៏ជាសរហ៍ពលគាំទ្រប្រជាជាតិ ។ ស្ម៏ឡាត្ម៏ប្រៀបបាននឹងរោងចក្រផលិតមនុស្ស ។ ស្ម៏ឡាត្ម៏ជាកំផែងដ៏មាំ, ចូរថែរក្សាវាឲ្យខ្ជាប់ខ្ជួន ។ ចូរកុំនិយាយ ឬស្រែកឡើងថា ពេលនេះ

បានទទួលហើយ ។"

## ផលប្រយោជន៍, ការយល់ដឹងនិងអាថ៌កំបាំងរបស់ស្វ៊ឡាត់

ស្វ៊ឡាត់ជាអ៊ីបាដាស់សំខាន់បំផុត ដែលបណ្តាសាស្តាបានផ្តែផ្តាំចំពោះបណ្តាបុត្ររបស់ព្រះអង្គ ។

ស្វ៊ឡាត់កំចាត់សេចក្តីវង្វេង និងជាការរំលឹកដល់អល់ឡោះហ្ 1ﷻ ។

ស្វ៊ឡាត់កំចាត់សេចក្តីច្រឡោងខាម, សេចក្តីក្រអឺត, ជួយគាំទ្រមនុស្សក្នុងការតស៊ូពុះពារឧបសគ្គ ទុក្ខលំបាក, និងជាការសម្តែងការអរព្រះគុណចំពោះព្រះមេត្តាធមិនាៗរបស់អល់ឡោះហ្ 1ﷻ ។

ស្វ៊ឡាត់ជាសសរកន្លោងនៃសាសនា ជាទង់ជ័យនៃសាសនាអ៊ីស្លាម ជាសោរនៃស្ថានសួគ៌ និងជាមធ្យោបាយត្រួតពិនិត្យប្រជារាស្ត្រ ។

ស្វ៊ឡាត់ជាគ្រឿងបន្សារភាពទន់ខ្សោយ និងតូចតាចភ្ជាប់នឹងភាពមហិមា, និងមានឥទ្ធិពលលើសអ្វីទាំងអស់ នោះគឺអល់ឡោះហ្ 1ﷻ ។

ព្រះសាស្តាអ៊ីសាعليه السلام នៅក្នុងគ្រែកូនង៉ែត បានមានវចនៈថា៖ "អល់ឡោះហ្ 1ﷻ ណែនាំឲ្យចេះប្រតិបត្តិស្វ៊ឡាត់" ។

អ៊ីមុាំអាលីﷺមានវចនៈថា ពេលព្រះអង្គﷺប្រតិបត្តិស្វ៊ឡាត់ ព្រះអង្គﷺបានចុះចូលក្រោមព្រះបារមីអល់ឡោះហ្ 1ﷻ ព្រះអង្គﷺភ្លេចអ្វីទាំងអស់ វៀរលែងអល់ឡោះហ្ 1ﷻមួយ ។

ស្វ៊ឡាត់ ២ រ៉ក្អាត់របស់អ្នកខ្លាចអល់ឡោះហ្ 1ﷻប្រសើរលើសស្វ៊ឡាត់ ១០០០ រ៉ក្អាត់របស់អ្នកមិនយកចិត្តទុកដាក់ មិនចេះពិចារណា ឬមិនខ្វល់ខ្វាយក្នុងការប្រតិបត្តិស្វ៊ឡាត់ ។

អ៊ីមុាំយ៉ាក្កុ់ហ្វារ អាស្វ៉ស្វ៊ឌិកﷺមានវចនៈថា៖ "ការក្រាបសាច់ដ្វាស់លើដីការបាឡាអ៉ុនោះ នឹងកើតមានរស្មីៗនេះនឹងកម្ទេចរបាំង



# បញ្ជីមាតិកា


ស្វ៊ឡាត់ (សំបាស់យ៉ាំង)........................................ ៩
ការសម្អាត........................................ ៩
វ៉ូឌូអ៊ុ (الوضوء)........................................ ១០
សំបាស់យ៉ាំងប្រចាំថ្ងៃ និងចំនួនរ៉ក្អាត់........................................ ១១
កន្លែងសំបាស់យ៉ាំង........................................ ១២
អាស្វាន (أذان) និងអ៊ីកុំម៉ាស់ (إقامة)........................................ ១៣
របៀបសូត្រអាស្វាន........................................ ១៣
របៀបសូត្រអ៊ីកុំម៉ាស់........................................ ១៤
សំបាស់យ៉ាំងស៊្ហុបហ៍ (صُبْح)........................................ ១៥
គីរ៉អាស់ (قِرَاءة ការសូត្រ)........................................ ១៦
រ៉ូគុអ៊ុ (رُكوع ឱន)........................................ ១៨
ស៊ូឃ្ជូដ (سُجود ការក្រាប)........................................ ១៩
គូនូត (ការលើកដៃសូមពរ)........................................ ២១
តាស្ហាស្ហ៊ុដ (تَشَهُّد)........................................ ២៤
តាស់លីម (تسليم សាឡាម)........................................ ២៤
រ៉ក្អាត់ទី ៣ និងរ៉ក្អាត់ទី ៤........................................ ២៥
តាស់ប៊ីហ្វាត អាល់-អារបាអាស់ ( التَسْبيحات الأرْبَعَة ការសូត្រសរសើរអល់ឡោះហ្ 1ﷻ)........................................ ២៦
តាយ៉ាំមុំ........................................ ២៨
រៀបប្រតិបត្តិគូស៊ូល (غسل)........................................ ២៩
ស្វ៊ឡាត់ (សំបាស់យ៉ាំង) ដែលអល់ឡោះហ្ 1ទទួល........................................ ៣១
លក្ខណ្ឌនៃអ៊ីបាដាស់ដែលត្រូវទទួល........................................ ៣១
ផលប្រយោជន៍, ការយល់ដឹងនិងអាថ៌កំបាំងរបស់ស្វ៊ឡាត់........................................ ៣៤

-ពេលបរិច្ចាគឃុំមស៍ និងស្ទាកាត់ គេចមិនព្រមបរិច្ចាគទេ ។
-អង្គុយជជែក និងនិយាយបង្ខូចអ្នកដទៃ ។
-កាត់ផ្តាច់មេត្រីភាពពីបងប្អូនមុស្លីម ។
-មានចិត្តគំនិតអាក្រក់ចំពោះអ្នកដទៃជានិច្ច និងលាក់ទុកនូវភាពជាសត្រូវនៅក្នុងចិត្ត ។
-មានឧបនិស្ស័យ និងមារយាទមិនល្អចំពោះអ្នកដទៃ ឬចំពោះជនរួមគ្រួសារ ទោះជាឪពុកក្តីម្តាយក្តី មិនប្រកបដោយអំពើល្អ ជាមូលហេតុធ្វើឲ្យអ្នកដទៃទទួលរងនូវសេចក្តីលំបាក និងការក្តៅក្រហាយ ។

ទាំងនេះគឺមូលហេតុដែលធ្វើឲ្យអ្នកដទៃបាត់បង់សិទ្ធិ និងជាមូលហេតុដែលធ្វើឲ្យឃ្លាតឆ្ងាយពីអល់ឡោះហ្ទ៍عزوجل ។ អ្នកណាប្រព្រឹត្តដូច្នេះ ចូរអ្នកនោះកុំសង្ឃឹមថាអល់ឡោះហ្ទ៍عزوجلនឹងទទួលស្ទ័ឡាត់ និងអ៊ីបាដាស់ផ្សេងៗរបស់ខ្លួនឡើយ ។
អ្នកស្ទ័ឡាត់ទាំងឡាយ ត្រូវតែធ្វើឲ្យស្ទ័ឡាត់របស់ខ្លួនទៅជាចំណងដ៏មាំដែលចងខ្លួនឯងជាប់នឹងអល់ឡោះហ្ទ៍عزوجل, ជាប់នឹងបងប្អូនញាតិមិត្ត និងជនដទៃ ។ ស្ទ័ឡាត់ត្រូវតែពុំមែនចំណងដែលបំផ្លិចបំផ្លាញសិទ្ធិជនដទៃឡើយ ។

តើយើងនឹងដឹងម្តេចបាន ថាអល់ឡោះហ្ទ៍عزوجلព្រមទទួលឬបដិសេធស្ទ័ឡាត់របស់យើងនោះ ? អ៊ីម៉ាំយ៉ាក្ញុំហ្វារ អាស់ស្ទ័ឌិកصلوات الله عليه والسلامមានវចនៈថា៖ "បុគ្គលណាមានបំណងចង់ដឹងថា ស្ទ័ឡាត់របស់ខ្លួនត្រូវទទួលឬទេនោះ ចូរអ្នកនោះពិចារណាមើលចុះថា ស្ទ័ឡាត់នោះបានការពារខ្លួនគេឲ្យឃ្លាតពីអំពើបាប និងអំពើអប្រិយឬទេ ? ទោះការពារបានតិចឬច្រើនក្តី ។ ដូច្នេះបើស្ទ័ឡាត់បានការពារគេឲ្យឃ្លាតពីការប្រព្រឹត្តខុស នឹងចាត់ទុកថាត្រូវ

នោះទុកឲ្យអ្នកនោះ ។ (ស៊ូរ៉ោះត៍ ២១, អាយ៉ាត់ ៩៤) ។"

២) អល់ឡោះហ្ទ៍ﷻទទួលកិច្ចការ និងអ៊ីបាដ្ទាស់របស់អ្នកណាដែលមានភ័ក្តីភាពចំពោះព្រះអង្គﷻ និងស្រឡាញ់បណ្ដាសាស្ដានិងបណ្ដាអ៊ីម៉ាំបរិសុទ្ធ ដោយព្រមទទួលព្រះអង្គទាំងនោះعليهم السلامជាអ្នកដឹកនាំ ជាអ្នកមានអំណាចក្នុងការថែរក្សា ។ ដូច្នេះ អ៊ីបាដ្ទាស់ណាដែលប្រាសចាកការព្រមទទួលស្គាល់នូវតំណែងវីឡាយ៉ាស់ អល់ឡោះហ្ទ៍ﷻនឹងមិនទទួលទេ; អ៊ីម៉ាំយ៉ាក់ហ្វារ អាស្ស៍ឌិក្វصلوات الله عليه والسلامធ្លាប់មានវចនៈថា៖ "អ្នកណាក៏ដោយដែលមិនព្រមទទួលតំណែងវីឡាយ៉ាស់របស់យើងទេ, អល់ឡោះហ្ទ៍នឹងមិនទទួលអ៊ុម៉ាល់របស់អ្នកនោះទេ ។"

៣) តាក់វ៉ា គឺការខ្លាចអល់ឡោះហ្ទ៍ ។ សេចក្ដីបរិសុទ្ធផុតពីបាប, ការចៀសអំពើដែលត្រូវហាម និងការប្រតិបត្តិស្ឡ៍ឡាត់ ដូចគ្នានឹងអ៊ីបាដ្ទាស់មួយដែលអល់ឡោះហ្ទ៍ﷻនឹងទទួលដែរ ពោលគឺ អល់ឡោះហ្ទ៍ﷻនឹងទទួលលុះណាតែប្រតិបត្តិទៅដោយសេចក្ដីក្រែងខ្លាចអល់ឡោះហ្ទ៍ﷻ ។ ពិតណាស់, អល់ឡោះហ្ទ៍ﷻនឹងមិនទទួលអ៊ីបាដ្ទាស់ ឬស្ឡ៍ឡាត់របស់អ្នកណាដែលប្រាសចាកសេចក្ដីក្រែងខ្លាចទេ, ដូចគួរអានថែងថា៖ "...អល់ឡោះហ្ទ៍ទទួលយក[តង្វាយ] តែពីអ្នកណាដែលជឿសប់ចិត្តទេ ។ (ស.៥, អ.២៧)" ។

៤) ស្ឡ៍ឡាត់ជាអ៊ីបាដ្ទាស់មួយ ដែលធ្វើខ្ញុំអល់ឡោះហ្ទ៍បានជិតស្និទ្ធនឹងអល់ឡោះហ្ទ៍ﷻ ។ បើអ្នកប្រតិបត្តិស្ឡ៍ឡាត់ប្រព្រឹត្តអំពើហាមឃាត់អល់ឡោះហ្ទ៍ﷻនឹងមិនគាប់ព្រះហឫទ័យទេ អល់ឡោះហ្ទ៍ﷻនឹងមិនទទួលស្ឡ៍ឡាត់នោះទេ ដូចជាបុគ្គលមួយចំនួនគឺ៖

-អ្នកជំពាក់បំណុលគេតែមិនព្រមសងបំណុលនោះទេ ។



بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

# សេចក្ដីផ្ដើម

អ៊ីម៉ាំអាលីصلوات الله عليه والسلامមានវចនៈថា៖ «ខ្ញុំដាក់បញ្ញាលើលោកទាំងអស់ជាដាច់ខាត ឲ្យព្យាយាមប្រឹងប្រែងប្រតិបត្តិស្ឡ៍ឡាត់ ព្រោះស្ឡ៍ឡាត់ជាអំពើដ៏ប្រសើរលើសអំពើទាំងអស់ ហើយជាសសរកន្លោងនៃសាសនារបស់លោកទាំងអស់ (ប៊ីហ្ារ អាល់-អាន់វ៉ារ) ។»

"...ចូរអ្នកធ្វើនមស្ការ ។ ការពិតធ្វើនមស្ការរាំងមិនឲ្យប្រព្រឹត្តអំពើអសីលធម៌និងអំពើអាក្រក់ ។ (ស. ២៩, អ.៤៥) ។"

អ៊ីម៉ាំអាលីصلوات الله عليه والسلامមានវចនៈថា៖ «អ្នកដែលបានទទួលការលុបលាងបាបគឺអ្នកប្រតិបត្តិស្ឡ៍ឡាត់ដោយស្គាល់តម្លៃ (មីស្ាន អ៊ុលហ្ិកម៉ាស់, ប៊ីហ្ារ អាល់-អាន់វ៉ារ) ។»

រ៉ស៊ូលុលឡោះហ្ទ៍ﷺមានព្រះវចនៈថា៖ «នាថ្ងៃគីយ៉ាម៉ាស់, អ្វីដែលគេនឹងពិនិត្យមើលមុនគេបង្អស់ ក្នុងចំណោមអំពើរបស់ខ្ញុំរាល់គ្នារបស់អល់ឡោះហ្ទ៍ﷻ គឺស្ឡ៍ឡាត់ ។ បើស្ឡ៍ឡាត់នោះត្រូវគេទទួល, គេនឹងពិនិត្យមើល(អំពើ)ផ្សេងទៀត, បើមិនត្រូវទទួលទេ គេនឹងមិនពិនិត្យមើលអំពើផ្សេងៗរបស់បាវនោះទេ (មីស្ាន អ៊ុលហ្ិកម៉ាស់, ប៊ីហ្ារ អាល់-អាន់វ៉ារ) ។»

អ្នកមានសទ្ធាទាំងអស់ ត្រូវជ្រាបនូវកំហិតនៃការប្រតិបត្តិស្ឡ៍ឡាត់, ដូចតទៅនេះគឺ៖

១-វ៉ាយ៉ិប (កំហិត) ប្រតិបត្តិស្ឡ៍ឡាត់ចាប់ពីពេញវ័យទៅ ពោលគឺ ចាប់ពីអាយុ ១៥ ឆ្នាំសម្រាប់មនុស្សប្រុស, ឯមនុស្សស្រីចាប់ពីអាយុ ៩ ឆ្នាំ ។

២-វ៉ាយ៉ិបឲ្យដឹងច្បាស់អំពីបញ្ញត្តិទាក់ទងនឹងការសង្ស័យ និងការភ្លេចភ្លាំង

ក្នុងពេលប្រតិបត្តិស្វ៍ឡាត់, ហើយក៏ត្រូវជ្រាបអំពីការប្រតិបត្តិតាមលោកបណ្ឌិតខាងសាសនាអ៊ីស្លាម (មុច្ថាហ៊ីដ្ឋ), និងមិនអនុញ្ញាតឲ្យប្រតិបត្តិតាម (តាក់លីដ្ឋ គឺការប្រតិបត្តិតាម) លោកបណ្ឌិតខាងសាសនាអ៊ីស្លាម (មុច្ថាហ៊ីដ្ឋ) ដែលរលត់ផុតទៅហើយទេ ។

៣-លក្ខណ្ឌរបស់លោកបណ្ឌិតជាន់ខ្ពស់នៃសាសនាអ៊ីស្លាម (មុច្ថាហ៊ីដ្ឋ) ដែលយើងប្រតិបត្តិតាមនោះត្រូវមានដូចតទៅនេះគឺ៖

-ជាមនុស្សពេញវ័យស្របតាមសាសនាអ៊ីស្លាម (បាលីក្ុ) ។

-មានសតិសម្បជញ្ញៈ ។

-ជឿអ៊ីម៉ាំទាំង១២ ។

-ជាមនុស្សប្រុស ។

-ជាមនុស្សដែលមានសមត្ថភាពវិនិច្ឆ័យ (អ៊ីច្ថីហាដ្ឋ) ។

-មានយុត្តិធម៌ ។

-មានកំណើតត្រឹមត្រូវតាមបទបញ្ញត្តិអ៊ីស្លាម (មិនមែនកូនស៊ីណា (زِنَى) ទេ) ។

-នៅរស់, មិនមែនរលត់ស្លាប់ផុតទៅហើយទេ ។

៤-វ៉ាយិប ឲ្យដឹងឬស្គាល់គីបឡាស់ (قِبْلَة) គឺទិសនៃបែទុលឡោះហ្វ៍; ហើយក៏ឲ្យចេះដឹងនូវការប្រតិបត្តិសំបាស់យ៉ាំង ក្នុងពេលធ្វើដំណើរដែលមានផ្លូវឆ្ងាយលើសពី ៨ ហ្វារសាក់ (២៤ ម៉ៃល៍ ឬ ៣៨ គីឡូម៉ែត្រ) ឬធ្វើដំណើរទៅមកមានផ្លូវឆ្ងាយស្មើនឹង ៨ ហ្វារសាក់ ។ ការប្រតិបត្តិសំបាស់យ៉ាំងក្នុងពេលធ្វើដំណើរនេះ សំបាស់យ៉ាំងដែលមាន ៤ រ៉ក្អាត់នោះនឹងធ្វើតែ ២ រ៉ក្អាត់, ដូចជាសំបាស់យ៉ាំងស្ហ៊ូហ្វូរ (ظُهْر), អាស្វារ (عَصْر) និងអ៊ីស្ហាអ៍ (عِشَاء), គឺនៅ ២ រ៉ក្អាត់ដូចសំបាស់យ៉ាំងស៊្វុបហ៍ (صُبْح); ឯសំយ៉ាំងម៉ាក់រីប (مَغْرِب) នោះនៅដូចដើម, គឺ ៣ រ៉ក្អាត់ដដែល ។

៥-សូត្រស៊្វរ៉ោះត៍ អាល់-ហ្វាទីហ៊ាស់ និង ស៊្វរ៉ោះត៍ផ្សេងៗ ក្នុងពេលសំបាស់យ៉ាំងស៊្វុបហ៍, ម៉ាក់រីប និង អ៊ីស្ហាអ៍ ឲ្យឮបង្គួរ ។ តែនៅពេល



វ៉ាយិប ឲ្យធ្វើគូស៊្វលឲ្យជាប់គ្នាកុំដាច់ ។

ពេលធ្វើគូស៊្វល ទឹកដែលយកមកប្រើត្រូវស្អាត និងបានទទួលការអនុញ្ញាតពីម្ចាស់ទឹកនោះ ។

ដូចគ្នា, ជាវ៉ាយិប, កន្លែងធ្វើគូស៊្វលនោះត្រូវបានទទួលការអនុញ្ញាតពីម្ចាស់វាសិន ។

ការនៀត (នឹកក្នុងចិត្ត) នោះពុំមែនការនិយាយទេ តែបើនិយាយចេញមកហើយទុកជាពុំខុស ។

បើមិនយកចិត្តទុកដាក់ក្នុងការធ្វើគូស៊្វល ដោយមិនគោរពពេលវេលាពីលំដាប់មួយទៅលំដាប់មួយ, ពោលគឺទុកពេលចោលឲ្យហួសទៅមុខ ត្រង់កន្លែងណាមួយ មិនត្រឹមត្រូវទេ ត្រូវធ្វើសាថ្មីជាចាំបាច់ ។

## ស្វ៍ឡាត់ (សំបាស់យ៉ាំង) ដែលអល់ឡោះហ្វ៍ទទួល

អ៊ីម៉ាំអាលីصلوات الله عليه والسلامមានវចនៈថា៖ "អាម៉ាល់ភាគច្រើនដែលត្រូវទទួលនោះគឺអាម៉ាល់ដែលបានប្រតិបត្តិដោយតាំងចិត្ត ។"

## លក្ខណ្ឌនៃអ៊ីបាដ្ហាស់ដែលត្រូវទទួល

១) លក្ខណ្ឌដំបូងគឺការមានសទ្ធាមាំចំពោះអល់ឡោះហ្វ៍عزّ وجلّ និងសាសនារបស់ព្រះអង្គعزّ وجلّ បុគ្គលណាមួយបានប្រតិបត្តិអ៊ីបាដ្ហាស់មួយជីវិតលុះស្លាប់ តែនៅក្នុងចិត្តបុគ្គលនោះពុំមានជំនឿឡើយសោះនោះ, ពិតណាស់, អល់ឡោះហ្វ៍عزّ وجلّនឹងមិនទទួលស្វ៍ឡាត់របស់បុគ្គលនោះទេ, ដូចគួរអានថែងថា៖ "អ្នកណាមួយសាងអំពើល្អ [ផ្តល់ប្រយោជន៍ដល់សហាគមន៍មនុស្ស និងប្រព្រឹត្តដើម្បីអល់ឡោះហ្វ៍] ហើយជាអ្នកមានសទ្ធា គេនឹងមិនបដិសេធការខំប្រឹងប្រែងប្រព្រឹត្តរបស់អ្នកនោះទេ ។ យើងនឹងកត់ត្រាទង្វើ

គ្គុស្ល អៀរទីម៉ាស៊ី (ងូតដោយមុជក្នុងទឹក) ។

ហ្ការ៉ាំ មិនឲ្យស្ត្រីដែលកាន់សីលតមអាហារ (ស្ហៅម៍) ធ្វើគ្គុស្ល អៀរទីម៉ាស៊ីទេ ។ ឯអ្នកដែលទៅធ្វើពីធីហ្កាជ្ជ៍ឲ្យធ្វើគ្គុស្លតារទីប៊ី មិនឲ្យធ្វើគ្គុស្ល អៀរទីម៉ាស៊ីទេ ។

នៀតពេលធ្វើគ្គុស្លមានដូចតទៅនេះគឺ៖ *"ខ្ញុំធ្វើគ្គុស្លយ៉ាណាបាស្ញ, គ្គុស្ល ហៃ្កដ្ហ៍ (غُسل الحَيض), គ្គុស្ល នីហ្វាស់, គ្គុស្ល អ៊ីសទីហ្កាដ្ហោះត៍, គ្គុស្ល អាល់ម៉ៃយិត, និង គ្គុស្ល ណាស្សារ (غسل النذر) ឬគ្គុស្លក៏សាំ... គ្គុរបាតាន់ អ៊ីលឡុលឡោះហ្ញ៍ ។"*

ការប្រតិបត្តិគ្គុស្លតារទីប៊ី គឺចាប់ផ្តើមដោយស្រោចទឹកពីលើក្បាលដល់កព្រមទាំងនៀតផង ។ បន្ទាប់មកឲ្យស្រោចលើមួយចំហៀងខ្លួនខាងស្តាំ តាំងពីស្មារហូតដល់ចុងជើង; រួចហើយស្រោចលើមួយចំហៀងខ្លួនខាងឆ្វេង, ពីស្មារហូតដល់ចុងជើង ។ ការស្រោចទឹកលើខ្លួនទាំងខាងឆ្វេងនិងខាងស្តាំនេះ, ចាំបាច់ឲ្យទឹកហូរទៅលើខ្នាស់ទាំងពីរអន្លើនោះដែរ ។

វ៉ាជ្ជិប មុននឹងប្រតិបត្តិគ្គុស្ល៍ ត្រូវជម្រះខ្លួនឲ្យស្អាតជាមុនសិន ។ បើក្នុងពេលធ្វើគ្គុស្លនោះ ប៉ែកណាមួយនៃខ្លួននោះមិនទទឹកទេ ចាំបាច់ត្រូវធ្វើគ្គុស្លសាថ្មី ។

ការប្រតិបត្តិគ្គុស្ល អៀរទីម៉ាស៊ី ម្ចាស់ខ្លួនចាំបាច់ត្រូវនៅក្នុងទឹក ព្រមទាំងនៀត បន្ទាប់មកឲ្យមុជទៅក្នុងទឹក ដោយឲ្យទឹកលិចក្បាល ។ បើធ្វើគ្គុស្ល អៀរទីម៉ាស៊ី រួចហើយ ដឹងប្រាកដថាមានកន្លែងណាមួយនៃខ្លួនប្រាណនោះមិនទទឹក ការប្រតិបត្តិគ្គុស្លនេះខូច ត្រូវតែធ្វើសាថ្មីចាប់ពីដើមមក ។

ក្នុងពេលប្រតិបត្តិគ្គុស្ល វ៉ាជ្ជិបឲ្យដុសខ្លួននិងឈ្លីសក់ ដើម្បីនឹងធ្វើឲ្យទឹកជ្រួតជ្រាបសព្វអន្លើនៃខ្លួនប្រាណ ។



សំបាស់យ៉ាំងស្ញ៊ស្ញ៊រ និង អ៊ុស្សារនោះត្រូវសូត្រដោយប្រើសម្លេងតិចៗ ឲ្យឮតែខ្លួនឯងប៉ុណ្ណោះ ។

៦-វ៉ាជ្ជិប ឲ្យដឹងថាសំបាស់យ៉ាំងត្រូវប្រតិបត្តិដោយលំដាប់, មិនឲ្យយកមុនទៅធ្វើក្រោយ ឬយកក្រោយធ្វើមុននោះទេ; និងត្រូវយល់គោលនៃជំនឿ (អ៊ីម៉ាន់) ដែលមាន ៥ ប្រការគឺ៖

១-តៅហ្ក៊ីដ្ឋ (تَوْحيد) គឺជឿជាក់ថាអល់ឡោះហ្ញ៍ជាព្រះតែមួយគត់, មិនមានអ្វី ឬអ្នកចូលរួមជាមួយឡើយ ។

២-អ៊ាឌ៊ីល (عادِل) ត្រូវជឿជាក់ថាអល់ឡោះហ្ញ៍មានយុត្តិធម៌ ទ្រង់មិនសង្កត់សង្កិនឬប្រព្រឹត្តអំពើផ្សេងៗដែលខុសនោះទេ ។

៣-នូប៊ូវ៉ាស្ញ (نُبُوَّة) ត្រូវជឿជាក់ថាអល់ឡោះហ្ញ៍បញ្ជូនសាសនទូតមកដើម្បីដឹកនាំប្រជាជាតិទាំងពួង ក្នុងការប្រតិបត្តិតាមព្រះបញ្ញត្តិរបស់អល់ឡោះហ្ញ៍តាអ៊ាឡា ។

៤-អ៊ីម៉ាម៉ាស្ញ (إِمَامَة) ត្រូវជឿជាក់ថាព្រះសាស្តាមូហ្កាំម៉ាដ្ឋ៍ ﷺ បានជ្រើសរើសអ្នកថែរក្សាបទបញ្ញត្តិរបស់អល់ឡោះហ្ញ៍តាអ៊ាឡា តាមព្រះបញ្ជារបស់ព្រះជាម្ចាស់ عز وجل, បុគ្គលទាំងនេះមិនត្រូវបានជ្រើសរើសឡើងដោយមនុស្សទេ ។ បុគ្គលទាំងប៉ុន្មាននាក់នេះគឺអ៊ីម៉ាំទាំង ១២ អង្គ عليهم السلام, មាននាមដូចតទៅនេះ គឺ៖

១-អ៊ីម៉ាំ អ៊ាលី បុត្ររបស់ អាប៊ូ ត្ហ៍លិប صلوات الله عليه والسلام ។
២- អ៊ីម៉ាំ ហ្កាសាន់ បុត្ររបស់អ៊ីម៉ាំ អ៊ាលី صلوات الله عليه والسلام ។
៣-អ៊ីម៉ាំ ហ្កូសៃន៍ បុត្ររបស់ អ៊ីម៉ាំ អ៊ាលី صلوات الله عليه والسلام ។
៤-អ៊ីម៉ាំ អ៊ាលី ស៊ៃនុល-អ៊ាប៊ីឌីន صلوات الله عليه والسلام ។
៥-អ៊ីម៉ាំ មូហាំម៉ាដ្ឋ៍ បាគ្គៀរ صلوات الله عليه والسلام ។
៦-អ៊ីម៉ាំ យ៉ាជ្អ៊ុហ្វារ ស្ហ៍ឌិក្ក صلوات الله عليه والسلام ។
៧-អ៊ីម៉ាំ មូសា កាស្ហ៊ិម صلوات الله عليه والسلام ។
៨-អ៊ីម៉ាំ អ៊ាលី រីដ្ហ៍ صلوات الله عليه والسلام ។

៩-អ៊ីម៉ាំ មូហាំម៉ាដ់ តាគ្គី អាល់-យ៉ាវ៉ាដ់ صلوات الله عليه والسلام ។

១០-អ៊ីម៉ាំ អាលី អាល់-ហាឌី صلوات الله عليه والسلام ។

១១-អ៊ីម៉ាំ ហាសាន់ អាស់ការី صلوات الله عليه والسلام ។

១២-អ៊ីម៉ាំ មូហាំម៉ាដ់ ម៉ាហ្ទី صلوات الله عليه والسلام ។

៥-គ្គីយ៉ាម៉ាត្ត់ ត្រូវជឿជាក់ថាថ្ងៃអវសាននៃលោកនេះនឹងកើតឡើង, នាថ្ងៃនោះហើយ ដែលវិញ្ញាណរបស់មនុស្សគ្រប់រូបនឹងត្រូវយកចេញមកដើម្បីនឹងចាំទទួលការកាត់ក្តីពីព្រះជាម្ចាស់عز وجل ថាតើកាលនៅមានជីវិតនៅលោកនេះបានធ្វើអំពើល្អ និងអំពើអាក្រក់ម្តេចខ្លះ, ហើយក៏ត្រូវដឹងនូវគោលនៃការប្រតិបត្តិសាសនា (ហ្វូរុអ៊ុដ្ឌឌីន) ដែលមាន ១០ ប្រការគឺ៖

១-ស្វឡាត្ត់ គឺសំបាស់យ៉ាំង ។

២-ស្វោម៍ (صوم) គឺការកាន់សីលតមអាហារ ។

៣-ស្សាកាត្ត់ (زَكَاة) ។

៤-យ្ហីហាដ់ (جِهَاد) ។

៥-ឃ្ហុមូស ឬ ឃ្ហុមស៍ (خُمْس) ។

៦-ហ្ហាច្ច (حَجّ) ។

៧-អាំរី ប៊ីល-ម៉ាក់រុហ្វ (الأ□ر بالمعروف) គឺការណែនាំឲ្យប្រតិបត្តិអំពើល្អ ។

៨-ណាហ៊ុ អាន់នីលមុនការ (النهي عن المنكر) គឺការហាមប្រព្រឹត្តអំពើអាក្រក់ ។

៩-តាវ៉ាល់ឡា (تَوَلَّى) គឺការស្រឡាញ់អាស្ល់លុល-បៃត៍របស់ព្រះសាស្តាصلى الله عليه وآله وسلم ។

១០-តាបារ៉អ៊ែ (تَبَرَّأَ) គឺការស្អប់ខ្ពើមសត្រូវរបស់អាស្ល់លុល-បៃត៍របស់ព្រះសាស្តាصلى الله عليه وآله وسلم ។



មក, ទទះដៃទាំងពីរឲ្យជីជាប់ដៃនោះជ្រុះ ។



២) យកដៃទាំងពីរនោះមកជូតមុខដោយចាប់ផ្តើមពីជើងសក់នៅបរិវេណថ្ងាសចុះមកដល់ខ្ទង់ច្រមុះ ។



៣) រួចហើយ, យកដៃឆ្វេងជូតលើខ្នងដៃស្តាំដោយចាប់ផ្តើមពីលើកដៃរហូតដល់ចុងម្រាមដៃ



៤) បន្ទាប់មកយកដៃស្តាំជូតលើខ្នងដៃឆ្វេង, ចាប់ពីខាងលើកដៃរហូតដល់ចុងម្រាមដៃ ។

ចូរប្រតិបត្តិតាមរូបភាពខាងលើនេះ ។

៥) អ៊ីសទីយ៉ាតវ៉ាយ៉ីប (ការប្រុងប្រយ័តវ៉ាយ៉ីប) ឲ្យយើងប្រតិបត្តិខចុងក្រោយនេះ (ខទី ៥), ទោះបីយើងធ្វើតាយ៉ាំមុំជួសវូឌុអ៍ឬជួសគ្គុស្វលក៏ដោយ គឺ៖ ឲ្យយើងយកបាតដៃទាំងពីរទះផង់ដីម្តងទៀត, បន្ទាប់មកដៃឆ្វេងជូតខ្នងដៃស្តាំ, រួចហើយយកដៃស្តាំជូតខ្នងដៃឆ្វេង ។

## រៀបប្រតិបត្តិគ្គុស្វល (غسل)

គ្គុស្វលមានពីរប្រភេទគឺ៖ គ្គុស្វលតារទីប៊ី (ងូតដោយស្រោចទឹក) និង

អាល់-អារបាអ៊ុាស់ ៣ ដង ។ រួចហើយរូគុអ៍, ហើយងើបឡើងវិញ ។ បន្ទាប់មកចុះសាច់ដ្ញាស់ ២ ដង, សូត្រតាស្ហាស់ហ៊្វុដនិងឲ្យសាឡាមបញ្ចប់សំបាស់យ៉ាំងម៉ាក់រីប ។

សំបាស់យ៉ាំងអុីស្ហាអ៍ (عِشَاء) មាន ៤ រ៉ក្អាត់ ។ ពេលរបស់វានៅក្រោយសំបាស់យ៉ាំងម៉ាក់រីប ។ របៀបប្រតិបត្តិដូចគ្នានិងរបៀបប្រតិបត្តិសំបាស់យ៉ាំងស្ហូហ៊្វូរនិងអាអ៊ុាស្ហូរដែរ ខុសតែនៀតប៉ុណ្ណោះគឺនៀតថា៖ *"ខ្ញុំសំបាស់យ៉ាំងអុីស្ហាអ៍ គ្ហូរបាតាន់ អុីលឡុលឡោះហ្វ៍ ។"*

សំបាស់យ៉ាំងទាំង ៥ នេះខុសគ្នាតែត្រង់ពេលសូត្រ អាល់ ហ្វាទីហាស់និងសូត្រស៊ូរ៉ោះត៍ផ្សេងៗ ។ ត្រូវសូត្រឲ្យឮបង្គួរពេលសំបាស់យ៉ាំងស្ហុបហ៍, ម៉ាក់រីបនិងអុីស្ហាអ៍ ។ តែត្រូវសូត្រឲ្យឮតិចៗល្មមតែឮខ្លួនឯងប៉ុណ្ណោះពេលសំបាស់យ៉ាំងស្ហូហ៊្វូរនិងអ៊ុាស្ហូរ ។

## តាយ៉ាំមុំ

តាយ៉ាំមុំគឺការសម្អាតដោយមិនប្រើទឹក ។ ឯរបៀបប្រតិបត្តិមានលំដាប់តិចជាងការប្រតិបត្តិវូឌុអ៍និងគុស៊ូល ។ មិនអនុញ្ញាតឲ្យធ្វើតាយ៉ាំមុំទេកាលណាមានទឹក ។

អនុញ្ញាតឲ្យធ្វើតាយ៉ាំមុំពេលដែលរកទឹកមិនបាន, ឬបើខ្លាចមានគ្រោះថ្នាក់ដល់ខ្លួនពេលប៉ះទឹក ក្នុងពេលធ្វើវូឌុអ៍ ឬធ្វើគុស៊ូលនោះ ។ ដូច្នេះ, ជាវ៉ាជីបត្រូវធ្វើតាយ៉ាំមុំ ។ របៀបធ្វើតាយ៉ាំមុំមានដូចតទៅនេះ គឺ៖

មុនប្រតិបត្តិតាយ៉ាំមុំត្រូវនៀតថា៖ *"ខ្ញុំធ្វើតាយ៉ាំមុំ គ្ហូរបាតាន់ អុីលឡុលឡោះហ្វ៍ ។"*

១) យកបាតដៃទាំងពីរទៅស្ទាប ឬទះផង់ដីដែលស្អាត ។ បន្ទាប់



អ្វីដែលធ្វើឲ្យសំបាស់យ៉ាំងខូចមានដូចតទៅនេះគឺ៖

១-ការបែរដងខ្លួនចេញពីគ៊ីបឡាត់ ឬបែរទៅទីណាមួយក៏ដោយ ។

២-និយាយក្នុងពេលសំបាស់យ៉ាំង ។

៣-សើចក្នុងពេលសំបាស់យ៉ាំង ។

៤-បរិភោគ ឬផឹក ទោះតិចក្ដីច្រើនក្ដី ។

៥-យំព្រោះតែមានកង្វល់ផ្លូវលោកនេះ; តែបើយំព្រោះខ្លាចការដាក់ទោសរបស់អល់ឡោះហ្វ៍តាអ៊ុាឡានោះអនុញ្ញាតឲ្យធ្វើបាន ។

៦-បើវូឌុអ៍ខូច, សំបាស់យ៉ាំងក៏ខូចដែរ ។

## ស្ហ៏ឡាត់ (សំបាស់យ៉ាំង)

អ្នកណាមិនបោះបង់សំបាស់យ៉ាំង ដែលជាព្រះបញ្ញត្តិមួយដ៏ចាំបាច់សម្រាប់ខ្លួនគេក្នុងគោលនៃការប្រតិបត្តិសាសនា (ហ្វ៊ូរអ៊ុដ្ឋឌីន) អ្នកនោះនឹងបានទទួលនូវរង្វាន់នៃព្រះមេត្តាធម៌ពីព្រះជាម្ចាស់عزّ وجلّ ។ អ្នកណាបោះបង់ចោលនូវសំបាស់យ៉ាំង រង្វាន់តបស្នងរបស់អ្នកនោះគឺភ្លើងនរកនិងការដាក់ទោសដ៏ធ្ងន់ ។ ពិតណាស់, ភ័ស្តុតាងនៃរឿងនេះមានច្រើននៅក្នុងគួរអាននិងហាឌីស្ហ ។

ដូច្នេះ, ចាំបាច់ត្រូវអធិប្បាយអំពីរឿងទូទៅដែលទាក់ទងនឹងសំបាស់យ៉ាំងជាចម្បង; បន្ទាប់មកនឹងអធិប្បាយអំពីការប្រតិបត្តិសំបាស់យ៉ាំង ។

## ការសម្អាត

អ្នកមានសទ្ធាទាំងឡាយ ត្រូវសម្អាតសម្លៀកបំពាក់និងខ្លួនប្រាណរបស់ខ្លួន ។ ដូច្នេះ មុននឹងសំបាស់យ៉ាំង យើងត្រូវធ្វើវូឌុអ៍ (ជម្រះខ្លួន) ជា

មុនសិន ដោយទឹកបរិសុទ្ធដែលមិនមានវត្ថុផ្សេងលាយ និងចាំបាច់ជាទឹកដែលបានយកមកពីអ្នកផ្សេងដោយបានទទួលការអនុញ្ញាត ។

## វូឌុអ៊ុ (الوضوء)



រូប ១

ចាប់ផ្តើមធ្វើវូឌុអ៊ុដោយនៀត (តាំងចិត្ត) ថា៖ *"ខ្ញុំធ្វើវូឌុអ៊ុ គួរបាតាន់ អ៊ីលឡុលឡោះហ្វ៍ ។"* នៀត (ការតាំងចិត្ត) ត្រូវធ្វើព្រមនឹងពេលលាងមុខ ដោយលាងពីជើងសក់, នាបរិវេណថ្ងាស, រហូតទៅដល់ចុងចង្កា ។ លាងសព្វផ្ទៃមុខ ដូចនៅលើរូបភាពទី ១ ។



រូប ២

បន្ទាប់មកលាងដៃ ដោយចាប់ផ្តើមលាងដៃស្តាំមុន ។ លាងចាប់ពីកែងដៃរហូតដល់ចុងម្រាមដៃ ។ បន្ទាប់មកលាងដៃឆ្វេង ដោយធ្វើដូចការលាងដៃស្តាំង ដូចនៅលើរូបភាពទី ២ ។



រូប ៣

រួចហើយធ្វើ "មាសាស់ (مسح)" (ការជូត) ចាប់ផ្តើមជូតក្បាលដោយប្រើដៃស្តាំ ដែលទទឹកស្រាប់ហើយនោះ (ពោលគឺមិនយកដៃស្តាំទៅលាងម្តងទៀតដើម្បីឲ្យវាទទឹកម្តងទៀតនោះទេ) ។ ឯក្បាលនោះវិញត្រូវស្ងួតមិនទទឹកទេ ពោលគឺមុននឹងជូតក្បាលៗនោះត្រូវស្ងួត មិនទទឹកស្រាប់ហើយទេ ។ ពេលជូត, ឲ្យជូតដោយអូសដៃមកខាងមុខ; មិនរុញទៅខាងក្រោយក្បាលនោះទេ ។ ដូចនៅលើរូបភាពទី ៣ ។

បន្ទាប់មកឲ្យជូតខ្នងជើងទាំងពីរ ។ ជូតខ្នងជើងស្តាំមុនដោយដៃស្តាំ, ពី



سُبْحَانَ اللهِ وَالْحَمْدُ لِلّٰهِ ស៊ុបហ្ហាណាល់ឡោះហ្វ៍ វ៉ាល់ហ្វាំឌុ លីលឡាស់
وَلَا إِلٰهَ إِلَّا اللهُ វ៉ា ឡា អ៊ីឡាហ្វា អ៊ីលឡុលឡោះហ្វ៍
وَاللهُ أَكْبَرُ វ៉ល់ឡហ៊ូ អាក់បារ

*អត្ថន័យ៖* សេចក្តីរុងរឿងជាកម្មសិទ្ធិរបស់អល់ឡោះហ្វ៍ﷻ, សេចក្តីសរសើរជាកម្មសិទ្ធិរបស់ ។ ពុំមានព្រះផ្សេងពីអល់ឡោះហ្វ៍ﷻឡើយ, អល់ឡោះហ្វ៍ﷻមហាធំធ្ងើង ។

សូត្រ ៣ ដង ។ រួចហើយចុះរូគុអ៊ុ, ដូចក្នុងរូបភាពទី ៧, និងសាច់ដ្ញាស់, ដូចរូបភាពទី ៨ និងរូបភាពទី ៩ ។ រួចហើយសូត្រតាស្ហាស់ហ្វ៊ូដនិងសាឡាម ។

អ្នកណាមួយមិនសូត្រស្វ៍ឡាវ៉ាតណាប៊ី និងក្រុមគ្រួសារបរិសុទ្ធព្រះអង្គﷺក្នុងសំបាស់យ៉ាំងទេ, សំបាស់យ៉ាំងរបស់អ្នកនោះទុកជាមោឃ: (បាតាល់) ។

សំបាស់យ៉ាំងអាស្វារ (عَصْر) មាន ៤ រ៉ក្អាត់, របៀបប្រតិបត្តិដូចសំបាស់យ៉ាំងស្ហ៊ូហ្វ៊ូរដែរ, ខុសតែនៀតប៉ុណ្ណោះគឺ៖ *"ខ្ញុំសំបាស់យ៉ាំងអាស្វារ គួរបាតាន់ អ៊ីលឡុលឡោះហ្វ៍ ។"*

សំបាស់យ៉ាំងម៉ាក់រីប (مَغْرِب) មាន ៣ រ៉ក្អាត់, របៀបប្រតិបត្តិដូចរបៀបសំបាស់យ៉ាំងស្ហ៊ុបហ្វ៍ដែរ, ខុសតែនៀតថា៖ *"ខ្ញុំសំបាស់យ៉ាំងម៉ាក់រីប គួរបាតាន់ អ៊ីលឡុលឡោះហ្វ៍ ។"* ពេលសូត្រតាស្ហាស់ហ្វ៊ូដរួច, ចុងរ៉ក្អាត់ទី ២, មុនឲ្យសាឡាម, តែយើងមិនឲ្យសាឡាមទេ, យើងក្រោកឈរឡើងដើម្បីប្រតិបត្តិរ៉ក្អាត់ទី ៣ ។ ឈរត្រង់ខ្លួនហើយឲ្យសូត្រតាស់ប៊ីហ្វាត់

(بِحَوْلِ اللهِ وَقُوَّتِهِ اَقُوْمُ وَاَقْعُدُ)[11] (ប៊ីហៅលីលឡាហ៊ី វ៉ា គូវ៉ាទីហ៊ី អាគូមូ វ៉ា អាក់អ៊ូដូ)

*អត្ថន័យ៖* ទូលព្រះបង្គំជាខ្ញុំក្រោកនិងអង្គុយ អាស្រ័យអំណាចនិងឥទ្ធិពលរបស់អល់ឡោះហ៍ ﷻ ។

## តាស់ប៊ីហាត អាល់-អារបាអ៊ាស់ ( التَسْبِيحات الأرْبَعَة ការសូត្រសរសើរអល់ឡោះហ៍ ﷻ)

ក្រោយពីឈរនឹងខ្លួនហើយ (ក្នុងរ៉ក្អាត់ទី ៣ នេះ), ដូចរូបភាពទី ៦, ឲ្យសូត្រថា៖

| | |
|---|---|
| سُبْحَانَ اللهِ وَالْحَمْدُ لِلّٰهِ | ស៊ុបហាណល់ឡោះហ៍ វ៉ាល់ហាំឌូ លីលឡាស់ |
| وَلَآ اِلٰهَ اِلَّا اللهُ | វ៉ា ឡា អ៊ីឡាហា អ៊ីលឡុលឡោះហ៍ |
| وَاللهُ اَكْبَرُ | វ៉ល់ឡ៉ហ៊ូ អាក់បារ |

*អត្ថន័យ៖* សេចក្តីរុងរឿងជាកម្មសិទ្ធិរបស់អល់ឡោះហ៍ ﷻ, សេចក្តីសរសើរជាកម្មសិទ្ធិរបស់អល់ឡោះហ៍ ﷻ ។ ពុំមានព្រះផ្សេងពីអល់ឡោះហ៍ ﷻ ឡើយ, អល់ឡោះហ៍ ﷻ មហាធំថ្កើង ។

សូត្រផ្ទួនៗ ៣ ដង, រួចហើយរូគុអ៊ុ, ដូចរូបភាពទី ៧ ។ បន្ទាប់មកចុះសាជ៉ុដ្ហាស់ពីរដង, ដូចក្នុងរូបភាពទី ៨ ។ នៅរវាងសាជ៉ូដ្ហាស់ទាំងពីរ, ឲ្យអង្គុយមួយភ្លែត, ដូចក្នុងរូបភាពទី ៩ ។ រួចសាជ៉ុដ្ហាស់ទាំងពីរហើយ, ឲ្យក្រោកឈរ, ដូចក្នុងរូបភាពទី ៦, ដើម្បីប្រតិបត្តិរ៉ក្អាត់ទី ៤, ហើយសូត្រថា៖

[11] ការសូត្រមួយឃ្លានៅក្នុងវង់ក្រចកនេះជាមុសតាហាប់ ។





រូប ៩

ចុងម្រាមជើងរហូតដល់ភ្នែកគោរ (កជើង) ។ រួចហើយជូតខ្នងជើងឆ្វេងដោយដៃឆ្វេង, របៀបជូតដូចគ្នា ។ ជើងទាំងពីរ, ក្នុងពេលជូត, ត្រូវស្ងួត មិនទទឹកស្រាប់ហើយទេ, ដូចក្បាលដែរ ។ ដូចនៅលើរូបភាពទី ៩ ។

## សំបាស់យ៉ាំងប្រចាំថ្ងៃ និងចំនួនរ៉ក្អាត់

វ៉ាជិបត្រូវដឹងពេលវេលារបស់សំបាស់យ៉ាំងប្រចាំថ្ងៃ និងចំនួនរ៉ក្អាត់របស់គ្រប់ៗសំបាស់យ៉ាំង ។ ព្រះសាស្តាមូហាំម៉ាដ់ ﷺ មិនបានបន្ថែម ឬបន្ថយពេលរបស់សំបាស់យ៉ាំងទាំងនោះទេ, ចំនួនពេលសំបាស់យ៉ាំងប្រចាំថ្ងៃទាំងនោះមាន ៥ ពេលគឺ៖

១) ពេលស៊ូបហ៍ (صُبْح) មាន២ រ៉ក្អាត់, ចាប់ពីសម្លេងអាសាន (أذان) ស៊ូបហ៍ទៅដល់ពេលថ្ងៃរះ ។

២) ពេលស៊ូហ៊្វូរ (ظُهْر) មាន ៤ រ៉ក្អាត់, ចាប់ពីសម្លេងអាសាន ស៊ូហ៊្វូរទៅដល់ថ្ងៃលិច ។

៣) ពេលអ៊ាស្វារ (عَصْر) មាន ៤ រ៉ក្អាត់, ចាប់ផ្តើមក្រោយពីសំយ៉ាំងស៊ូហ៊្វូររួចរហូតដល់ថ្ងៃលិច ។ និយាយឲ្យស្រួលស្តាប់ គឺក្រោយពីសំយ៉ាំងស៊ូហ៊្វូររួចភ្លាមយើងអាចសំយ៉ាំងអ៊ាស្វារបានភ្លាម, ដោយមិនបាច់រង់ចាំពេលអ៊ាស្វារ ។ តែបើរង់ចាំឲ្យដល់ពេលសំយ៉ាំងអ៊ាស្វារនោះក៏មិនខុសទេដែរ; ហើយក្នុងពេលអ៊ាស្វារនេះ យើងសំយ៉ាំងបានតែអ៊ាស្វារមួយប៉ុណ្ណោះ, មិនអាចសំយ៉ាំងស៊ូហ៊្វូរជាមួយផងបានទេ ព្រោះជាពេលសម្រាប់តែអ៊ាស្វារមួយ

ប៉ុណ្ណោះ ។

នៅក្នុង ស្វ៍ហ៊ិះហ៍ ប៊ូខ៏រី លោក អ៊ីបនូ អ៊ុមើរ បាស់មានប្រសាសន៍ថា៖ "រ៉សូលុលឡោះហ៍ ﷺ បានប្រតិបត្តិ ៧ រ៉ក្អាត់ជាមួយគ្នា (សំយ៉ាំង ម៉ាក់រីបនិងអ៊ីស្ហាអ៍), ហើយព្រះអង្គ ﷺ បានប្រតិបត្តិ ៨ រ៉ក្អាត់ ជាមួយគ្នា (សំយ៉ាំងស្ហ៊ូហ៊្វរនិងអ៊ាស្វរ) ។" លោកមុស្លីមក៏មាន ប្រសាសន៍ដូច្នេះដែរ ។

៤) ពេលម៉ាក់រីប (مَغْرِب) មាន ៣ រ៉ក្អាត់ ចាប់ផ្ដើមពីថ្ងៃលិចទៅ, ពី សម្លេងអាស្ហានម៉ាក់រីប រហូតជិតដល់អធ្រាត្រ ។

៥) ពេលអ៊ីស្ហាអ៍ (عِشَاء) មាន ៤ រ៉ក្អាត់, ចាប់ផ្ដើមក្រោយពីសំយ៉ាំង ម៉ាក់រីបរួចរហូតជិតទៅដល់អធ្រាត្រ ។ និយាយឲ្យស្រួលស្ដាប់គឺ ក្រោយពីសំយ៉ាំងម៉ាក់រីបរួចភ្លាម យើងអាចសំយ៉ាំងអ៊ីស្ហាអ៍ភ្លាម បាន, ដោយមិនបាច់រង់ចាំឲ្យពេលអ៊ីស្ហាអ៍មកដល់ទេ ។ តែបើចង់ សំយ៉ាំងនៅពេលរបស់អ៊ីស្ហាអ៍តែម្ដងក៏បាន, មិនខុសទេ; ហើយ ក្នុងពេលនេះយើងសំយ៉ាំងបានតែអ៊ីស្ហាអ៍មួយប៉ុណ្ណោះ, សំយ៉ាំង ម៉ាក់រីបជាមួយផងមិនបានទេ ព្រោះជាពេលសម្រាប់តែអ៊ីស្ហាអ៍ មួយប៉ុណ្ណោះ ។

## កន្លែងសំបាស់យ៉ាំង

ជាវ៉ាយ៉ីបសម្រាប់អ្នកសំបាស់យ៉ាំង, កន្លែងដែលឲ្យសំបាស់យ៉ាំងបាន នោះគឺកន្លែងដែលប្រាសចាកសេចក្ដីស្មោកគ្រោក (ណាយ៉ីស) ដែល សាសនាដាក់បញ្ញត្តិមក និងជាកន្លែងដែលបានទទួលការអនុញ្ញាតពី



اَلسَّلَامُ عَلَيْنَا وَعَلٰى عِبَادِ اللهِ អាស់អាឡាមូ អ៊ុឡៃណា វ៉ាអ៊ុឡា អ៊ីបាឌីលឡា
الصَّالِحِيْنَ السَّلَامُ عَلَيْكُمْ ហ៊ីស្វស្វ៍លីហ៊ីន អាស់សាឡាមូអ៊ុឡៃគុំ
وَرَحْمَةُ اللهِ وَبَرَكَاتُهُ វ៉ា រោះហ៍ម៉ាទុលឡ៍ហ៊ី វ៉ា បារ៉កាទុះហ៍

*អត្ថន័យ៖* (ឱណាបី សូមឲ្យសិរីសួស្ដីនិងព្រះពររបស់អល់ឡោះហ៍កើត មានដល់ព្រះអង្គ ។) សូមឲ្យសិរីសួស្ដីកើតមានដល់ទូលព្រះបង្គំជាខ្ញុំ ទាំងឡាយ និងមានដល់បាវទាំងឡាយរបស់អល់ឡោះហ៍ ។ សូមឲ្យ សិរីសួស្ដីមានដល់ព្រះអង្គទាំងឡាយ ព្រមទាំងព្រះមេត្តាធម៌និងព្រះពរ របស់អល់ឡោះហ៍ផងដែរ ។

ក្រោយពីបានសូត្រចប់ហើយ, សំបាស់យ៉ាំងស្វុបហ៍ (صُبْح) ក៏ចប់ត្រឹម នេះដែរ ។ តទៅនេះយើងអធិប្បាយអំពីសំបាស់យ៉ាំងដែលមានបីរ៉ក្អាត់ និងបួនរ៉ក្អាត់ ។

## រ៉ក្អាត់ទី ៣ និងរ៉ក្អាត់ទី ៤

បើសំបាស់យ៉ាំងបួនរ៉ក្អាត់, របៀបប្រតិបត្តិដូចនឹងសំបាស់យ៉ាំងស្វុបហ៍ ដែរ ខុសតែនៀតប៉ុណ្ណោះ ។

ពេលសំបាស់យ៉ាំងស្ហ៊ូហ៊្វរ (ظُهْر), យើងនៀតថា៖ *"ខ្ញុំសំបាស់យ៉ាំង ស្ហ៊ូហ៊្វរ គួរបាតាន់ អ៊ីលឡុលឡោះហ៍"* ។
ក្រោយពីបានសូត្រតាស្ហាស់ហ៊្វុដរួចហើយ, នៅចុងរ៉ក្អាត់ទី ២, ឲ្យ ក្រោកឈរឡើងដើម្បីប្រតិបត្តិរ៉ក្អាត់ទី ៣, ដោយសូត្រក្នុងពេលក្រោក ឈរឡើងនេះថា៖

## តាស្ហាស់ហ៊្ហុដ (تَشَهُّد)

ពេលអង្គុយក្រោយពីបានស៊ូយ៉ូដពីរដងក្នុងរ៉ក្អាត់ទី ២, ឲ្យសូត្រតាស្ហាស់ហ៊្ហុដដូចតទៅនេះ គឺៈ

| | |
|---|---|
| اَشْهَدُ اَنْ لَّآ اِلٰهَ اِلَّا اللّٰهُ | អាស្ហ់ហ្ហាឌុ អាល់ឡា អ៊ីឡាហ្ហា អ៊ីលឡុលឡោះហ្ហ៍ |
| وَحْدَهٗ لَا شَرِيْكَ لَهٗ وَاَشْهَدُ | វ៉ាស់ដ្ហាស់ ឡា ស្ហារីកាឡាស់ វ៉ា អាស្ហ់ហ្ហាឌុ |
| اَنَّ مُحَمَّدًا عَبْدُهٗ وَرَسُوْلُهٗ | អាន់ណា មូហ្ហាំម៉ាដ្ហាន់ អាប់ឌុហ្ហូ វ៉ា រ៉ស៊ូលុះហ្ហ៍ |
| اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَّاٰلِ مُحَمَّدٍ | អល់ឡ៉ហ៊ុំម៉ា ស្វល់លី អាឡា មូហ្ហាំម៉ាដ្ហ វ៉ា អាលី មូហ្ហាំម៉ាដ្ហ |

*អត្ថន័យៈ* ទូលព្រះបង្គំជាខ្ញុំសូមប្ដេជ្ញាជាឧឡារិកថាពុំមានព្រះផ្សេងពីអល់ឡោះហ្ហ៍عزّ وجلّទ្បើយ, ព្រះអង្គعزّ وجلّជាឯកអាទិទេព, ពុំមានអ្វីប្រៀបប្រដូចព្រះអង្គعزّ وجلّបានឡើយ ។ ទូលព្រះបង្គំជាខ្ញុំសូមប្ដេជ្ញាថាមូហ្ហាំម៉ាដ្ហعزّ وجلّជាបម្រើនិងជាព្រះសាស្ដារបស់ព្រះអង្គعزّ وجلّ ។ សូមអល់ឡោះហ្ហ៍عزّ وجلّប្រទានពរជ័យសិរីសួស្ដីដល់មូហ្ហាំម៉ាដ្ហនិងក្រុមគ្រួសារព្រះអង្គعليهم السلام ។

## តាស់លីម (تسليم សាឡាម)

បន្ទាប់ពីនោះមកសូត្រតាស់លីម (សាឡាម) ដូចតទៅនេះ គឺៈ

| | |
|---|---|
| [10](اَسَّلَامُ عَلَيْكَ اَيُّهَا النَّبِيُّ وَرَحْمَةُ اللهِ وَبَرَكَاتُهٗ) | (អាស់អាឡាមុ អាឡៃកា អៃយូហ្ហាន់ណាប៊ីយូ វ៉ា រ៉ោះហ្ហ៍ម៉ាទុលឡ៉ហ្ហិ វ៉ា បារ៉កាទុះហ្ហ៍) |

[10] ការសូត្រមួយឃ្លានៅក្នុងវង់ក្រចកនេះជាមុសតាហ្ហាប់ ។



ម្ហាស់កន្លែងនោះ ។

## អាស្ហាន (أذان) និងអ៊ីក៉ូម៉ាស្ហ់ (إِقَامَة)

ក្រោយពីបានប្រតិបត្តិវ៉ូឌុអ៊ុំហើយ, អ្នកសំបាស់យ៉ាំងត្រូវឈរបែរមុខទៅឯគ៊ីបឡាត់ សូត្រអាស្ហាននិងអ៊ីក៉ូម៉ាស្ហ់ជាភាសាសារ៉ាប់ឲ្យត្រឹមត្រូវ ។

## របៀបសូត្រអាស្ហាន

| | |
|---|---|
| اَللّٰهُ أَكْبَرُ. اَللّٰهُ أَكْبَرُ. اَللّٰهُ أَكْبَرُ. اَللّٰهُ أَكْبَرُ. | អល់ឡ៉ហ្ហ៊ូ អាក់បារ (៤ ដង) |
| أَشْهَدُ أَنْ لاَ إِلَهَ إِلاَّ اَللّٰهُ. أَشْهَدُ أَنْ لاَ إِلَهَ إِلاَّ اَللّٰهُ. | អាស្ហ់ហ្ហាឌុ អាល់ឡា អ៊ីឡាហ្ហា អ៊ីលឡុលឡោះហ្ហ៍ (២ ដង) |
| أَشْهَدُ أَنَّ مُحَمَّدًا رَسُولُ اَللّٰهِ. أَشْهَدُ أَنَّ مُحَمَّدًا رَسُولُ اَللّٰهِ. | អាស្ហ់ហ្ហាឌុ អាន់ណា មូហ្ហាំម៉ាដ្ហាន់ រ៉ស៊ូលុលឡោះហ្ហ៍ (២ ដង) |
| [1](أَشْهَدُ أَنَّ عَلِيّاً وَلِيُّ اَللّٰهِ. أَشْهَدُ أَنَّ عَلِيّاً وَلِيُّ اَللّٰهِ) | (អាស្ហ់ហ្ហាឌុ អាន់ណា អាលីយ៉ោ វ៉ាលីយុលឡោះហ្ហ៍ (២ ដង) |
| حَيَّ عَلَى اَلصَّلاَةِ. حَيَّ عَلَى اَلصَّلاَةِ. | ហៃយ៉ា អាឡាស្ហ់ស្វឡាស្ហ់ (២ ដង) |
| حَيَّ عَلَى اَلْفَلاَحِ. حَيَّ عَلَى اَلْفَلاَحِ. | ហៃយ៉ា អាឡាល់ហ្វាឡាស្ហ់ (២ ដង) |
| حَيَّ عَلَى خَيْرِ اَلْعَمَلِ. حَيَّ عَلَى خَيْرِ اَلْعَمَلِ. | ហៃយ៉ា អាឡា ខ៊ូយ់រីល អាម៉ាល់ (២ ដង) |

[1] ការសូត្រ أَشْهَدُ أَنَّ عليًا ولي الله. أَشْهَدُ أَنَّ عليًا ولي الله នេះមិនមែននៅក្នុងអាស្ហាននិងអ៊ីក៉ូម៉ាស្ហ់តែម្ដងទេ, យកល្អឲ្យសូត្រក្រោយពីសូត្រព្រះនាមរបស់រ៉ស៊ូលុលឡោះហ្ហ៍صلى الله عليه وآله وسلم ។ តែបើមិនសូត្រក៏មិនខុសទេ ។

| | |
|---|---|
| اَللّٰهُ أَكْبَرُ. اَللّٰهُ أَكْبَرُ. | អល់ឡ៉ហ្វ អាក់បារ (២ ដង) |
| لَا إِلٰهَ إِلاَّ اللّٰهُ. | ឡា អ៊ីឡាហ្វា អ៊ីលឡុលឡោះហ្វ៍ (១ ដង) |

## របៀបសូត្រអ៊ីកុ៏ម៉ាស់

| | |
|---|---|
| اَللّٰهُ أَكْبَرُ. اَللّٰهُ أَكْبَرُ. | អល់ឡ៉ហ្វ អាក់បារ (២ ដង) |
| أَشْهَدُ أَنْ لَا إِلٰهَ إِلاَّ اللّٰهُ. أَشْهَدُ أَنْ لَا إِلٰهَ إِلاَّ اللّٰهُ. | អាស្ហ៊ុហ្វាឌូ អាល់ឡា អ៊ីឡាហ្វា អ៊ីលឡុលឡោះហ្វ៍ (២ ដង) |
| أَشْهَدُ أَنَّ مُحَمَّدًا رَسُولُ اللّٰهِ. أَشْهَدُ أَنَّ مُحَمَّدًا رَسُولُ اللّٰهِ. | អាស្ហ៊ុហ្វាឌូ អាន់ណា មូហ្ហាំម៉ាដ្ឌាន់ រ៉ស៊ូលុលឡោះហ្វ៍ (២ ដង) |
| (أَشْهَدُ أَنَّ عَلِيّاً وَلِيُّ اللّٰهِ. أَشْهَدُ أَنَّ عَلِيّاً وَلِيُّ اللّٰهِ)[2] | (អាស្ហ៊ុហ្វាឌូ អាន់ណា អ៊ាលីយ៉ៅ វ៉ាលីយុលឡោះហ្វ៍ (២ ដង) |
| حَيَّ عَلَى الصَّلاَةِ. حَيَّ عَلَى الصَّلاَةِ. | ហៃយ៉ា អ៊ុឡាស្វ៉ុស្វ៊ូឡាស៊ុ (២ ដង) |
| حَيَّ عَلَى الْفَلاَحِ. حَيَّ عَلَى الْفَلاَحِ. | ហៃយ៉ា អ៊ុឡាល់ហ្វាឡាស៊ុ (២ ដង) |
| حَيَّ عَلَى خَيْرِ الْعَمَلِ. حَيَّ عَلَى خَيْرِ الْعَمَلِ. | ហៃយ៉ា អ៊ុឡា ខ៉ុយរីល អ៊ុម៉ាល់ (២ ដង) |
| قَدْ قَامَتِ الصَّلاَةُ. قَدْ قَامَتِ الصَّلاَةُ. | កូដ្ឌ កុ៏ម៉ាទីស្វ៉ុស្វ៊ូឡាស៊ុ (២ ដង) |
| اَللّٰهُ أَكْبَرُ. اَللّٰهُ أَكْبَرُ. | អល់ឡ៉ហ្វ អាក់បារ (២ ដង) |

[2] ការសូត្រមួយឃ្លានៅក្នុងវង់ក្រចកនេះជាមុសតាហ្ហាប់ (مستحبّ), មានន័យថា "យកល្អគួរធ្វើ" ។ តែបើមិនធ្វើក៏មិនខុសទេដែរ ។



រួចហើយងើបឡើងវិញមកឈរត្រង់ នឹងខ្លួនហើយឲ្យសូត្រថាៈ

(سَمِعَ اللّٰهُ لِمَنْ حَمِدَهُ)[9] (សាមីអុល់ឡ៉ហ្វ លីម៉ាន់ ហ្ហាមីដ្ឌាស៊ុ)

*អត្ថន័យៈ* អល់ឡោះហ្វ៍ទ្រង់សវនាការអ្នកសរសើរព្រះអង្គ ﷻ ។

បន្ទាប់មកដាក់ខ្លួនចុះសាច់ដ្ឋាស៊ុ ដូចរ៉ក្អាត់ដំបូង, ដូចក្នុងរូបភាពទី ៨, ហើយសូត្រថាៈ

| | |
|---|---|
| سُبْحَانَ رَبِّيَ الْأَعْلَى وَبِحَمْدِهِ | ស៊ុបហ្ហាណា រ៉ប់ប៊ីយ៉ាល់អាក់ុឡា វ៉ាប៊ីហ្ហាំឌិះហ្វ៍ |
| (اللّٰهُمَّ صَلِّ عَلَى مُحَمَّدٍ وَآلِ مُحَمَّدٍ) | (អល់ឡ៉ហ៊ុមម៉ា ស្វល់លី អ៊ុឡា មូហ្ហាំម៉ាដ្ឌ វ៉ា អាលី មូហ្ហាំម៉ាដ្ឌ) |

*អត្ថន័យៈ* សូមថ្វាយសេចក្តីរុងរឿងនិងការសរសើរចំពោះព្រះជាម្ចាស់ ﷻ របស់ទូលព្រះបង្គំជាខ្ញុំ ព្រះអង្គ ﷻ ទ្រង់មហាខ្ពង់ខ្ពស់ (សូមអល់ឡោះហ្វ៍ ﷻ ប្រទានពរជ័យសិរីសួស្តីដល់មូហ្ហាំម៉ាដ្ឌនិងក្រុមគ្រួសារព្រះអង្គ عليه السلام)

បន្ទាប់ពីនោះមកងើបឡើងអង្គុយ, ដូចក្នុងរូបភាពទី ៩, ហើយសាច់ដ្ឋាស៊ុម្តងទៀត, ដូចក្នុងរូបភាពទី ៨ ហើយសូត្រដូចពេលសាច់ដ្ឋាស៊ុដំបូង ។

[9] ការសូត្រមួយឃ្លានៅក្នុងវង់ក្រចកនេះជាមុសតាហ្ហាប់ ។

رَبَّنَا آتِنَا فِي الدُّنْيَا حَسَنَةً وَفِي الْآخِرَةِ حَسَنَةً وَقِنَا عَذَابَ النَّارِ

រ៉ប់បាណា អាទីណា ហ្វីដ្ឌុនយ៉ា ហ្វាសាណាតៅ វ៉ា ហ្វីលអាឃ៊ីរ៉ទី ហ្វាសាណាតៅ វ៉ាគ៊ីណា អាុស្ាបាន់ណារ

*អត្ថន័យៈ* សូមព្រះជាម្ចាស់ﷻរបស់ទូលព្រះបង្គំជាខ្ញុំទាំងឡាយប្រទានអ្វីៗដ៏ល្អប្រសើរនាលោកនេះ និងអ្វីៗដ៏ល្អប្រសើរនាលោកខាងមុខ; និងសូមព្រះអង្គﷻមេត្តាជួយឲ្យទូលបង្គំជាខ្ញុំទាំងឡាយចៀសផុតពីការរងទុក្ខនៃនរកផង ។

យើងអាចសូត្រគូនូតផ្សេងៗច្រើនទៀតបាន ។

ក្រោយពីនោះមក ដាក់ដៃចុះឈរត្រង់ខ្លួន, ដូចរូបភាពទី ៦; ហើយចុះរូគុអ៊ ដូចរូគុអ៊រ៉ក្អាត់ដំបូង និងឲ្យសូត្រក្នុងពេលរូគុអ៊នេះថាៈ

سُبْحَانَ رَبِّيَ الْعَظِيمِ وَبِحَمْدِهِ — ស៊ុបហ្វាណា រ៉ប់ប៊ីយ៉ាល់ អាុស្ទីមី វ៉ាប៊ីហ្វាំឌិះហ្វ៍

(اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ وَآلِ مُحَمَّدٍ)[8] — (អល់ឡ៉ហ្វុមម៉ា ស្វល់លី អាុឡា មូហ្វាំម៉ាដ៉ុ វ៉ា អាលី មូហ្វាំម៉ាដ៉ុ)

*អត្ថន័យៈ* សូមថ្វាយសេចក្ដីរុងរឿងនិងការសរសើរចំពោះព្រះជាម្ចាស់ﷻរបស់ទូលព្រះបង្គំជាខ្ញុំ ព្រះអង្គﷻទ្រង់មហាធំធ្លើង (សូមអល់ឡោះហ្វ៍ﷻប្រទានពរជ័យសិរីសួស្ដីដល់មូហ្វាំម៉ាដ៉ុនិងក្រុមគ្រួសារព្រះអង្គﷺ) ។

[8] ការសូត្រមួយឃ្លានៅក្នុងវង់ក្រចកនេះជាមុសតាហ្វាប់ ។



لَا إِلَهَ إِلَّا اللَّهُ. — ឡា អ៊ីឡាហ្វា អ៊ីលឡុលឡោះហ្វ៍ (១ ដង)

## សំបាស់យ៉ាំងស៊ុបហ្វ៍ (صُبْح)

អ្នកសំបាស់យ៉ាំង ចាំបាច់ត្រូវនៀត (តាំងចិត្ត) ថាខ្លួនសំបាស់យ៉ាំងអ្វី, ដូចនេះគឺៈ *"ខ្ញុំសំបាស់យ៉ាំងស៊ុបហ្វ៍ (صبح)* (គឺប្រាប់ឈ្មោះសំបាស់យ៉ាំងដែលខ្លួនតាំងចិត្តប្រតិបត្តិ) *គួរបាតាន់ អ៊ីលឡុលឡោះហ្វ៍ ។"*





រូប ៦

បន្ទាប់មក លើកដៃទាំងពីរឡើងជិតត្រចៀក ដោយឈរបែរមុខទៅឯគិបឡាត់ ហើយសូត្រថា *"អល់ឡ៉ហ្វូ អាក់បារ"* ។ ការសូត្រដូចនេះហៅថា "តាក់បៀរទុល-អិះហ្វ៉ារ៉ម", វ៉ាយីបឲ្យសូត្រឲ្យឮបង្គួរ មិនឲ្យសូត្រដោយសម្លេងតិចទេ; ដូចរូបភាពទី ៥ ។



រូប ៥

បន្ទាប់មក ដាក់ដៃទាំងពីរចុះស្របដងខ្លួនដូចរូបភាពទី ៦ ។ ក្រោយពីបាននៀតហើយ

បើមិនបានសូត្រគាត់បៀរទុលអ៊ិះហ្ព៍រ៉មទេ, សំបាស់យ៉ាំងរបស់ខ្លួនត្រូវខូច ទោះភ្លេច ឬដោយចេតនាមិនធ្វើក៏ដោយ ព្រោះគាត់បៀរទុលអ៊ិះហ្ព៍រ៉មជារូកុនមួយដូចរូកុនឯទៀត, ដូចរូគុអ៊ុំនិងការឈរត្រង់ខ្លួនរវាងរូគុអ៊ុំ, ដូចការឈប់សម្រាកមុនស៊ូយ៉ូដជាដើម ។

## គ្វីរ៉អាស្ញ (قِرَاءَة ការសូត្រ)

បន្ទាប់មក ឲ្យសូត្រស៊ូរ៉េាះត៏ហ្វាទីហ៊ាស្ញដូចនេះគឺះ

| | |
|---|---|
| بِسْمِ اللهِ الرَّحْمٰنِ الرَّحِيْمِ | ប៊ីស មីលឡាហ្ហៀរ៉េាះហ្ព៍ម៉ា នៀរ៉ហ្ពីម |
| اَلْحَمْدُ لِلّٰهِ رَبِّ الْعٰلَمِيْنَ | អាល់ហ្ពាំឌូ លីលឡាហ្ហ៊ី រ៉ប់ប៊ីល អ៊ាឡាមីន |
| الرَّحْمٰنِ الرَّحِيْمِ | អាររ៉េាះហ្ព៍ម៉ា នៀរ៉ហ្ពីម |
| مٰلِكِ يَوْمِ الدِّيْنِ | ម៉ាលីគី យ៉ៅមីដ្ឌីន |
| اِيَّاكَ نَعْبُدُ وَاِيَّاكَ نَسْتَعِيْنُ | អ៊ីយ៉ាកា ណាក់ប៊ូឌូ វ៉ាអ៊ីយ៉ាកា ណាស់តាអ៊ីន |
| اِهْدِنَا الصِّرَاطَ الْمُسْتَقِيْمَ | អ៊ិះហ្ទ៍ឌីណាស្ញស៊ីរ៉ត្វល់មុសតាគ្វីម |
| صِرَاطَ الَّذِيْنَ اَنْعَمْتَ عَلَيْهِمْ | ស៊ីរ៉ត្វល់ឡាស៊ីណា អាន់អាំតា អាឡៃហ៊ីម |
| غَيْرِ الْمَغْضُوْبِ عَلَيْهِمْ وَلاَ الضَّآلِّيْنَ | ក្ញយ់រីលម៉ាក់ឌូប៊ី អាឡៃហ៊ីម វ៉ាឡាដ្ឌល់លីន |

*អត្ថន័យះ* ដោយនូវព្រះនាមអល់ឡោះហ្ញ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។ សូមថ្វាយសេចក្តីស៊ើចសរសើរចំពោះអល់ឡោះហ្ញ ព្រះម្ចាស់នៃពិភពទាំងពួង ។ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។ ព្រះម្ចាស់នៃថ្ងៃជំនុំជម្រះ ។ ព្រះអង្គទេ



៨ ។ បន្ទាប់ពីនោះមកងើបអង្គុយវិញ, ដូចរូបភាពទី ៩ ។ នេះជាការបញ្ចប់រ៉ក្អាត់ទី ១ ។ រួចហើយងើបឈរត្រង់ខ្លួនវិញ, ដូចរូបភាពទី ៦; ហើយក្នុងពេលដែលងើបឡើងឈរវិញនេះឲ្យសូត្រថាះ

(بِحَوْلِ اللهِ وَقُوَّتِهِ اَقُوْمُ وَاَقْعُدُ)[7] (ប៊ីហ្ពៅលីលឡាហ្ហ៊ី វ៉ា គូវ៉ាទីហ្ហ៊ី អាគូមូ វ៉ា អាក់អ៊ូដូ)

*អត្ថន័យះ* ទូលព្រះបង្គំជាខ្ញុំក្រោកនិងអង្គុយ អាស្រ័យអំណាចនិងឥទ្ធិពលរបស់អល់ឡោះហ្ញ ﷻ ។

ពេលឈរត្រង់ខ្លួន នឹងខ្លួនហើយ, ដូចក្នុងរូបទី៦, ឲ្យសូត្រស៊ូរ៉េាះត៏អាល់ហ្វាទីហ៊ាស្ញនិងសូត្រស៊ូរ៉េាះត៏ណាមួយ ក្រៅពីស៊ូរ៉េាះត៏ដែលមានសាច់ដ្ញាស្ញវ៉ាយ៉ីប ។

## គូនូត (ការលើកដៃសូមពរ)

ជាមុសតាហ៊ាប់ ។ ឲ្យធ្វើគូនូតដោយលើកដៃទាំងពីរឡើងដូចឌូអ៊ាអ៊ុំ, ដូចរូបភាពទី ១០, ហើយសូត្រថាះ



រូប១០

[7] ការសូត្រមួយឃ្លានៅក្នុងវង់ក្រចកនេះជាមុសតាហ៊ាប់ ។

វ៉ា អាលី មូហ៊ាំម៉ាដ្ទ)

*អត្ថន័យ៖* សូមថ្វាយសេចក្ដីរុងរឿងនិងការសរសើរចំពោះព្រះជាម្ចាស់របស់ទូលបង្គំ ព្រះអង្គﷻទ្រង់មហាខ្ពង់ខ្ពស់ (សូមអល់ឡោះហ្ញ៍ﷻប្រទានពរជ័យសិរីសួស្ដីដល់មូហ៊ាំម៉ាដ្ទនិងក្រុមគ្រួសារព្រះអង្គعليه السلام) ។

រួចហើយងើបមកអង្គុយ, ដូចរូបភាពទី ៩, ហើយឲ្យសូត្រថា៖

(اَسْتَغْفِرُ اللهَ رَبِّي وَاَتُوبُ اِلَيْهِ)[6] (អាស់តាក់ហ្វ៊ីរុលឡោះហ្ញ៍ រ៉ប់ពី វ៉ា អាទូប៊ូ អ៊ីឡៃហ្ញ៊ី)

*អត្ថន័យ៖* សូមអល់ឡោះហ្ញ៍ﷻអភ័យទោសឲ្យទូលព្រះបង្គំជាខ្ញុំផង ។ ទូលព្រះបង្គំជាខ្ញុំសូមត្រឡប់មករកព្រះអង្គﷻវិញ (ផ្លាស់ចិត្តគំនិតមកធ្វើល្អវិញ) ។



រូប ៩

បន្ទាប់ពីនោះមកសាច់ដ្ញាស់ម្ដងទៀត ដូចសាច់ដ្ញាស់ដំបូង, រូបភាពទី

[5] ការសូត្រមួយឃ្លានៅក្នុងវង់ក្រចកនេះជាមុសតាហ្ហាប់ (مستحبّ), មានន័យថា "យកល្អគួរធ្វើ" ។ តែបើមិនធ្វើក៏មិនខុសទេដែរ ។

[6] ការសូត្រមួយឃ្លានៅក្នុងវង់ក្រចកនេះជាមុសតាហ្ហាប់ (مستحبّ), មានន័យថា "យកល្អគួរធ្វើ" ។ តែបើមិនធ្វើក៏មិនខុសទេដែរ ។



ដែលអស់ទូលព្រះបង្គំជាខ្ញុំគោរពបូជា ព្រះអង្គទេដែលអស់ទូលព្រះបង្គំជាខ្ញុំអង្វរសូមនូវជំនួយ ។ សូមព្រះអង្គមេត្តាដឹកនាំអស់ទូលព្រះបង្គំជាខ្ញុំឆ្ពោះទៅកាន់មាគ៌ាត្រង់ត្រូវ ។ មាគ៌ារបស់បណ្ដាអ្នកដែលព្រះអង្គបានព្រះរាជទានឲ្យនូវឧបការធម៌[ពិសេសនៃព្រះអង្គ] ពុំមែនបណ្ដាអ្នកដែល[ប្រទូសប្រឆាំងបណ្ដាព្រះសាស្ដារបស់អល់ឡោះហ្ញ៍ និងចំពោះសិក្ខាបទរបស់ព្រះអង្គដែល]ទទួលរងនូវព្រះពិរោធ[នៃព្រះអង្គ]ទេ ហើយក៏ពុំមែនបណ្ដាអ្នកវង្វេងខុសទេដែរ [និងមិនស្ថិតនៅលើមាគ៌ានៃព្រះអង្គទេ] ។

ចប់ហើយត្រូវសូត្រស៊ូរ៉ោះត៍ណាមួយ, ឧទាហរណ៍ ស៊ូរ៉ោះត៍ អាល់-អ៊ីខ្លាស់ ជាដើម គឺ៖

| | |
|---|---|
| بِسْمِ اللهِ الرَّحْمَنِ الرَّحِيْمِ | ប៊ីស មីលឡាហ្ញៀររ៉ោះហ៍ម៉ានៀររ៉ហ៊ីម |
| قُلْ هُوَ اللهُ اَحَدٌ | គ្មុល ហ៊ូវ៉ល់ឡ៏ហ៊ូ អាហាដ្ទ |
| اَللهُ الصَّمَدُ | អល់ឡ៏ហ៊ុស្ស៍ម៉ាដ្ទ |
| لَمْ يَلِدْ وَلَمْ يُوْلَدْ | ឡាំ យ៉ាលីដ្ទ វ៉ា ឡាំ យូឡាដ្ទ |
| وَلَمْ يَكُنْ لَّهٗ كُفُوًا اَحَدٌ | វ៉ាឡាំ យ៉ាគុលឡាហ៊ូ គូហ្វ៊ូវ៉ាន់ អាហាដ្ទ |

*អត្ថន័យ៖* ចូរអ្នកថា៖ "ព្រះអង្គគឺអល់ឡោះហ្ញ៍ ព្រះមួយគត់ ។ អល់ឡោះហ្ញ៍ ព្រះអនន្ត ។ ព្រះអង្គមិនឲ្យកំណើតទេ ព្រះអង្គមិនត្រូវប្រសូតមកទេ ។ ពុំមានអ្វីដូចព្រះអង្គឡើយ ។"

ការសូត្រស៊ូរ៉ោះត៍ក្រោយពីសូត្រអាល់-ហ្វាទីហ្ហាស់, អាចសូត្រស៊ូរ៉ោះត៍ណាមួយក៏បាន លើកលែងតែស៊ូរ៉ោះត៍ណាដែលមានសាច់ដ្ញាស់ (គឺមានស៊ូយ៉ូដ) វ៉ាយិប ដែលមាន ៤ គឺ៖ ស៊ូរ៉ោះត៍ ៣២ អាយ៉ាត់ ១៥; ស៊ូរ៉ោះត៍

៨១ អាយ៉ាត់ ៣៧; ស៊ូរ៉ោះត៍ ៥៣ អាយ៉ាត់ចុងក្រោយបំផុត; ស៊ូរ៉ោះត៍ ៩៦ ពីរអាយ៉ាត់ចុងក្រោយ ។

## រូគុអ៊ ( رُكوع ឱន)

បន្ទាប់ពីនោះមកឲ្យរូគុអ៊ (ឱន) ដោយយកដៃទាំងពីរដាក់លើជង្គង់ទាំងសងខាង ដូចរូបភាពទី ៧ ។ បន្ទាប់មកឲ្យសូត្រក្នុងពេលកំពុងរូគុអ៊នេះថា៖



រូប ៧

سُبْحَانَ رَبِّيَ الْعَظِيْمِ وَبِحَمْدِهِ — ស៊ុបហ្ហាណា រ៉ប់ប៊ីយ៉ាល់អ៊ុស្ស៊ីម វ៉ា ប៊ីហ្ហាំឌិះហ៊្

(اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَّآلِ مُحَمَّدٍ)[3] — (អល់ឡ៉ហ៊ុម្ម៉ា ស្វល់លី អ៊ាឡា មូហ្ហាំម៉ាដ៏ វ៉ា អាលី មូហ្ហាំម៉ាដ៏)

*អត្ថន័យ៖* សូមថ្វាយសេចក្តីរុងរឿងនិងការសរសើរចំពោះព្រះជាម្ចាស់ ﷻ របស់ទូលបង្គំជាខ្ញុំ ព្រះអង្គ ﷻ ទ្រង់មហាធំធ្ងើង (សូមអល់ឡោះហ៍ ﷻ

[3] ការសូត្រមួយឃ្លានៅក្នុងវង់ក្រចកនេះជាមុសតាហ្ហាប់ (مستحبّ), មានន័យថា "យកល្អគួរធ្វើ" ។ តែបើមិនធ្វើក៏មិនខុសទេដែរ ។



ប្រទានពរជ័យសិរីសួស្តីដល់មូហាំម៉ាដ៏និងក្រុមគ្រួសារព្រះអង្គ ﷺ) ។

បន្ទាប់ពីនោះមកឲ្យក្រោកឈរត្រង់ខ្លួនឡើងវិញ ដូចរូបភាពទី ៦ ហើយឲ្យសូត្រថា៖

(سَمِعَ اللهُ لِمَنْ حَمِدَهُ)[4] (សាមីអ៊ុល់ឡ៉ហ៊ូ លីម៉ាន់ ហ្ហាមីដាហ៊្)

*អត្ថន័យ៖* អល់ឡោះហ៍ ﷻ ទ្រង់សវនាការអ្នកសរសើរព្រះអង្គ ﷻ ។

## ស៊ូយ៉ូដ ( سُجود ការក្រាប)

បន្ទាប់មកដាក់ខ្លួនចុះស៊ូយ៉ូដ ដោយដាក់ថ្ងាសផ្ទាប់លើបន្ទះដី, ដាក់ដៃទាំងពីរ, ដាក់ក្បាលជង្គង់ទាំងពីរ, ដាក់ចុងមេជើងទាំងពីរ នៅលើផ្ទៃរាប, ដូចរូបភាពទី ៨ ។



រូប ៨

ក្នុងពេលស៊ូយ៉ូដនេះឲ្យសូត្រថា៖

سُبْحَانَ رَبِّيَ الْأَعْلٰى وَبِحَمْدِهِ — ស៊ុបហ្ហាណា រ៉ប់ប៊ីយ៉ាល់អាក់ឡា វ៉ា ប៊ីហ្ហាំឌិះហ៊្

(اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَّآلِ مُحَمَّدٍ)[5] — (អល់ឡ៉ហ៊ុម្ម៉ា ស្វល់លី អ៊ាឡា មូហ្ហាំម៉ាដ៏

[4] ការសូត្រមួយឃ្លានៅក្នុងក្រចកនេះជាមុសតាហ្ហាប់, យកល្អគួរធ្វើ ។ តែបើមិនធ្វើទេក៏មិនខុសទេដែរ ។